**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

| |
|---|
| តុលាការខេត្តកំពង់ធំ |
| សាលក្រម |
| លេខ ៤៦ ក ចុះថ្ងៃទី ១៨ |
| ខែ តុលា ឆ្នាំ ២០០៥ |
| សំណុំរឿង |
| លេខ ១១៥ ចុះថ្ងៃទី ២៩ |
| ខែ កញ្ញា ឆ្នាំ ២០០៥ |

សាលក្រមនេះចូលជាស្ថាពរចាប់ពីថ្ងៃទី ១៨ ខែ ធ្នូ ឆ្នាំ ២០០៥ តទៅ
ដោយគ្មានការតវ៉ាតាមផ្លូវច្បាប់ ។
កំពង់ធំ, ថ្ងៃទី ១៩ ខែ ធ្នូ ឆ្នាំ ២០០៥
ព្រះរាជអាជ្ញាអមតុលាការខេត្ត
[redacted]

## តាងនាមប្រជារាស្ត្រខ្មែរ

តុលាការខេត្តកំពង់ធំ បង្កើតឡើងតាមច្បាប់ស្តីពីការចាត់តាំង និង សកម្មភាពរបស់សាលាជំរះក្តីនៃរដ្ឋកម្ពុជា ដែលប្រកាសឱ្យប្រើតាមក្រឹត្យលេខ ០៦ក្រ ចុះថ្ងៃទី ០៨ ខែ កុម្ភៈ ឆ្នាំ ១៩៩៣ ។

បានបើកសវនាការជាសាធារណៈ នៅទាទីតុលាការខេត្តកំពង់ធំ ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៥ ដោយមានសមាសភាពដូចតទៅ:

**ចៅក្រមជំនុំជំរះ**

លោក [redacted]

**តំណាងអយ្យការ**

លោក [redacted]

**ក្រឡាបញ្ជីសវនាការ**

លោក [redacted]

ដើម្បីជំនុំជំរះរឿងក្តីរដ្ឋប្បវេណីលេខ ១១៥ ចុះថ្ងៃទី ២៩ ខែ កញ្ញា ឆ្នាំ ២០០៥ ដែលមានកម្មវត្ថុបណ្តឹង : **ប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធ និង សុំគ្រប់គ្រងកូនចំនួន ០២នាក់ ។**

-រវាងដើមចោទ ឈ ឈម ហៅ ឆិត ភេទប្រុស អាយុ ៣៨ឆ្នាំ របររកស៊ីបើកបររថយន្ត នៅភូមិកំពង់ក្របៅ ឃុំកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ ម ឈ (ស) ម្តាយឈ្មោះ ទ ប (រ) ប្រពន្ធឈ្មោះ ន ទរ មានកូន ០២នាក់ ។

-និង ចុងចម្លើយឈ្មោះ ន ទរ ហៅ ឌួច ភេទស្រី អាយុ ៣៥ឆ្នាំ របររកស៊ីបុគ្គលិក ធនាគារជាតិ សព្វថ្ងៃនៅភូមិកំពង់ក្របៅ ស្រុកស្ទឹងសែន ខេត្តកំពង់ធំ ឪពុកឈ្មោះ ម គន (រ) ម្តាយឈ្មោះ ភ មស (រ) ប្តីឈ្មោះ ឈ ឈម មានកូន ០២ នាក់ ។

-បានឃើញរបាយការណ៍ជូនរឿងជំនុំជំរះលេខ ៧៣៩ ចុះថ្ងៃទី ១៨ ខែ សីហា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពង់ធំ ។

-បានឃើញដីកាចាត់តាំងចៅក្រមជំនុំជំរះលេខ ៧៩២ ចុះថ្ងៃទី ០១ ខែ កញ្ញា ឆ្នាំ ២០០៣ របស់តុលាការខេត្តកំពង់ធំ ។

## ឯរឿងហេតុមានដូចតទៅ

តាមពាក្យបណ្តឹងចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ឈ ឈម បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្រពន្ធឈ្មោះ ន ទរ ដោយហេតុថា : ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយឈ្មោះ ន ទរ ត្រឹមត្រូវតាមប្រពៃណីកាលពីថ្ងៃទី ១០

ខែ មករា ឆ្នាំ ១៩៩២ ។ បន្ទាប់ពីបានរៀបការរួចមកនៅរួមរស់ជាមួយគ្នាបានសេចក្តីសុខជាមួយគ្នាជាធម្មតាទេ រហូតបានកូនស្រី ០២នាក់ គឺ :

១-ឈ្មោះ ឈ **ហន្ស** អាយុ ១២ឆ្នាំ

២-ឈ្មោះ ឈ **ហម** អាយុ ០៦ឆ្នាំ ។

ការរួមរស់នៅជាមួយគ្នារហូតដល់ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៤ មានទំនាស់គ្នាដោយប្រពន្ធប្រច័ណ្ឌ ថា ខ្លួនមានស្រីកកើតទំនាស់គ្នារកាំរកូសជាប្រចាំ រួចក៏ចុះបែកលំនៅសង្វាសពីខ្លួនរហូតសព្វថ្ងៃនេះ ។

ដូច្នេះខ្លួនប្តឹងសុំអោយបានដាច់សមត្ថសង្វាសពីគ្នាតាមច្បាប់តទៅ ដោយអស់មនោសញ្ចេតនានឹងគ្នាជាប្តី ប្រពន្ធតទៅទៀតហើយ ។

កូន ០២នាក់សុំសិទ្ធិគ្រប់គ្រង និង មិនមានទាមទារប្រាក់អាហារកិច្ចចិញ្ចឹមកូនទេ ។

ទ្រព្យសម្បត្តិដើមរបស់ខ្លួនគ្មានទេ ។ ចំណែកទ្រព្យសម្បត្តិរួមក៏គ្មានដែរ ។

## <u>នាពេលសវនាការ</u>

-ដើមចោទឈ្មោះ **ឈ ឈហ** ឆ្លើយថា ខ្លួនរៀបអាពាហ៍ពិពាហ៍ជាមួយចុងចម្លើយជាប្រពន្ធឈ្មោះ **ន ទរ** កាលពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ២០០៥ រួមរស់នៅជាមួយគ្នាបានកូន ០២នាក់ ។

-កូនទី១ ឈ្មោះ ឈ **ហន្ស** ភេទស្រី អាយុ ១២ឆ្នាំ

-កូនទី២ ឈ្មោះ ឈ **ហម** ភេទស្រី អាយុ ០៦ឆ្នាំ ។

ទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមគ្មានទេ ។

រួមរស់នៅជាមួយគ្នារហូតដល់ថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥ មានទំនាស់ជាមួយគ្នាដោយខ្លួនមាន ស្រឡាញ់ស្រីផ្សេង ហើយចុងចម្លើយក៏បានចុះបែកលំនៅសង្វាសចាប់ពីពេលនេះមករហូតដល់បច្ចុប្បន្នមានរយៈពេល មួយឆ្នាំមកហើយ ទើបប្តឹងលែងលះមកនេះ ។

-ចុងចម្លើយឈ្មោះ **ន ទរ** បានឆ្លើយថា ខ្លួនបានរៀបអាពាហ៍ពិពាហ៍ជាមួយដើមចោទជាប្តីប្រពន្ធ និង គ្នា ដូចការអះអាងរបស់ដើមចោទប្រាកដមែន ។ ចំពោះទំនាស់ក្នុងគ្រួសាររវាងខ្លួន និង ដើមចោទមិនអាចសំរុះសំរួល បានទេ ដោយខ្លួនបានចុះបែកលំនៅសង្វាសតាំងពីថ្ងៃទី ០៧ ខែ មិថុនា ឆ្នាំ ២០០៥ រហូតមកហើយ ។

ចំពោះទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមគ្មានទេ ។ កូនមាន ០២នាក់ ដូចចម្លើយរបស់ដើមចោទពី ខាងដើម គឺខ្លួនសុខចិត្តប្រគល់កូនទាំង ០២នាក់អោយទៅដើមចោទចិញ្ចឹមគ្រប់គ្រង ដោយសុំអោយបានដាច់សមត្ថ សង្វាសពីគ្នាតាមច្បាប់ ។

## <u>តំណាងអយ្យការបានធ្វើសេចក្តីសន្និដ្ឋានថា</u> :

ចំពោះរឿងក្តីនេះអយ្យការទុកសិទ្ធិជូនតុលាការសំរេចទៅតាមច្បាប់ ។

-ក្រោយពីបានស្តាប់ដើមចោទឆ្លើយអោយការណ៍ និង ប្តឹងសុំ

-ក្រោយពីបានស្តាប់ចម្លើយដោះសាររបស់ចុងចម្លើយ

-ក្រោយពីបានស្តាប់សេចក្តីសន្និដ្ឋានរបស់តំណាងអយ្យការ

-ក្រោយពីបានពិនិត្យត្រឹមត្រូវតាមច្បាប់ហើយ

CS CamScanner

## តុលាការខេត្តកំពង់ធំ

-យល់ឃើញថា : ពាក្យបណ្តឹងចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ឈ ឈម មានលក្ខណៈត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

-យល់ឃើញថា : ដើមចោទឈ្មោះ ឈ ឈម បានប្តឹងសុំផ្តាច់សមគ្គសង្វាសពីប្តីឈ្មោះ ន ទរ ដោយសំអាងហេតុថា ខ្លួនបានរៀបការជាមួយចុងចម្លើយជាប្តីប្រពន្ធ នឹងគ្នា តាំងពីថ្ងៃទី ១០ ខែ មករា ឆ្នាំ ១៩៩២ រួមរស់នៅជាមួយគ្នាមានកូន ០២នាក់ ខ្លួនអស់មនោសញ្ចេតនាពីប្រពន្ធដោយខ្លួនបានបែកលំនៅសង្វាសពីគ្នាជាងមួយឆ្នាំហើយ ។

-យល់ឃើញថា : មានភស្តុតាងគ្រប់គ្រាន់បញ្ជាក់ថា ដើមចោទ និង ចុងចម្លើយពិតជាបានរៀបអាពាហ៍ពិពាហ៍ជាប្តីប្រពន្ធនឹងគ្នាត្រឹមត្រូវតាមច្បាប់ពីឆ្នាំ ១៩៩២ ហើយស្ម័គ្រចិត្តលែងលះដោយអស់មនោសញ្ចេតនានឹងគ្នាប្រាកដមែន ។

-យល់ឃើញថា : គូភាគីបានព្រមព្រៀងឯកភាពគ្នាប្រគល់កូន ០២នាក់ កូនទី១ ឈ្មោះ ឈ មឡ ភេទស្រី អាយុ ១២ឆ្នាំ និង កូនទី២ ឈ្មោះ ឈ មម ភេទស្រី អាយុ ០៦ឆ្នាំ អោយទៅដើមចោទចិញ្ចឹមគ្រប់គ្រង ។

-យល់ឃើញថា ទ្រព្យសម្បត្តិដើម និង ទ្រព្យសម្បត្តិរួមរបស់គូភាគីគ្មានទេ ។

## ហេតុដូច្នេះតុលាការខេត្តកំពង់ធំ
## វិនិច្ឆ័យសេចក្តី

១-ទទួលពាក្យបណ្តឹងចុះថ្ងៃទី ២៨ ខែ សីហា ឆ្នាំ ២០០៥ របស់ដើមចោទឈ្មោះ ឈ ឈម ហៅ ធិត ទុកជាត្រឹមត្រូវតាមទម្រង់ និង គតិច្បាប់ ។

២-សំរេចឱ្យដើមចោទឈ្មោះ ឈ ឈម និង ចុងចម្លើយឈ្មោះ ន ទរ ដាច់សមគ្គសង្វាសពីគ្នា តាមបញ្ញត្តិមាត្រា ៤០ នៃច្បាប់អាពាហ៍ពិពាហ៍ និង គ្រួសារ ចាប់ពីសាលក្រមនេះមានអានុភាពអនុវត្តតទៅ ។ ដាក់កំហុសលើដើមចោទ ។

៣-ឱ្យឈ្មោះនាង ន ទន ស្ថិតនៅក្នុងភាពមេម៉ាយចំនួន ៣០០ថ្ងៃគិតចាប់ពីថ្ងៃប្រកាសសាលក្រមនេះតទៅ ។

៤-ប្រគល់ ០២នាក់ កូនទី១ ឈ្មោះ ឈ មឡ ភេទស្រី អាយុ ១២ឆ្នាំ និង កូនទី២ ឈ្មោះ ឈ មម ភេទស្រី អាយុ ០៦ឆ្នាំឱ្យទៅដើមចោទឈ្មោះ ឈ ឈម គ្រប់គ្រងចិញ្ចឹមថែរក្សា តាមការព្រមព្រៀងឯកភាពរបស់គូភាគី ។ ទុកសិទ្ធិឱ្យចុងចម្លើយទៅសួរសុខទុក្ខកូនបានតាមមាត្រា ៧៥ នៃច្បាប់ស្តីពីអាពាហ៍ពិពាហ៍ និង គ្រួសារ ។

៥-រឹបអូសប្រាក់ប្រដាប់ក្តី គឺពន្ធចុះបញ្ជីក្តី ពន្ធហ្វីង ១.៨០០រ០០ រង្វាន់ក្រឡាបញ្ជីកាន់ហិបប្រាក់ ២០០រ០០ រង្វាន់ប្រគល់ដីកាកោះ ៥.០០០រ០០ សរុប ៧.០០០រ០០ ប្រាក់នេះបានកាត់យកពីប្រាក់ ៧.០០០រ០០ ដែលដើមចោទបានបង់រួចហើយ ។

CamScanner

៦-សាលក្រមនេះជំនុំជំរះ និង ប្រកាសជាសាធារណៈចំពោះមុខគូក្តី ទុកសិទ្ធិប្តឹងក្នុងរយៈពេល ០២ខែ តាមកំណត់ច្បាប់ ។

**ចៅក្រមជំនុំជំរះ**

[redacted]

CamScanner